**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកែប**
សំណុំរឿងព្រហ្មទណ្ឌលេខ ០៤
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ ២៥ "ឃ"
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកែប

បានបើកសវនាការពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រាំបី និង សាមសិប នាទីព្រឹក ។

ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកែប

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកែប

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកែប

**តុលាការ**

-**បានឃើញ**៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ០១ អ.យ.គ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**៖ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ២១ អ.យ.គ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**៖ ដីកាដំណោះស្រាយលេខ៖ ២៥/២៣ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកែប។

-**បានឃើញ**៖ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកែប។

-**បានឃើញ**៖ ដីកាសម្រេចដាក់រឿងជំនុំជម្រះ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកែប។

-**បានឃើញ**៖ ការផ្តល់ដំណឹងពីកាលបរិច្ឆេទនៃសវនាការតាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៤ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ដែលមាន៖

## ជនជាប់ចោទ

១.ឈ្មោះ [redacted] លីម ភេទប្រុស កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកែប អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកែប ឪពុកឈ្មោះ[redacted]គីម "ស" ម្ដាយឈ្មោះ [redacted] សារុន "រ" កម្រិតវប្បធម៌រៀនថ្នាក់ទី១១ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៣) ។

ជាប់ចោទពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសីករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] សុភ័ក្រ ហៅ[redacted] សុភ័ក្រ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិត្រ[redacted] ខេត្តកំពត អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកែប ឪពុកឈ្មោះ[redacted] ប៉ុ "ស" ម្ដាយឈ្មោះ [redacted]សុគីម "រ" ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូន ០២នាក់ កម្រិតវប្បធម៌រៀនថ្នាក់ទី០៧ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣) ។

៣.ឈ្មោះ [redacted] ផន ហៅក្ដាមប្រែ ភេទប្រុស អាយុ ៣៥ឆ្នាំ (កើតឆ្នាំ១៩៨៨) ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិអូ[redacted] ខេត្តកំពត អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិអ[redacted] ខេត្តកែប ឪពុកឈ្មោះ [redacted] ផៃ "រ" ម្ដាយឈ្មោះ [redacted] ខុម "រ" ប្រពន្ធឈ្មោះ [redacted] យ៉ាត មានកូន ០៣នាក់ កម្រិតវប្បធម៌រៀនថ្នាក់ទី១១ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣) ។

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសីករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកមេធាវី [redacted] សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាសយដ្ឋានក្រុមហ៊ុនមេធាវីយុត្តិធម៌អន្តរជាតិ អគារលេខ VA-540 ផ្លូវវិមានអាហារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ផន) ។

## អង្គហេតុនៃបណ្ដឹងចោទប្រកាន់

កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង២១ និង ២០នាទី យប់ កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនបានចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសីករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដោយបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] លីម ភេទប្រុស អាយុ ៣៣ឆ្នាំ ដែលបានទិញថ្នាំញៀនពីឈ្មោះ ផន ដើម្បីយកទៅលក់បន្តក្នុងតម្លៃ ៤០,០០០ ៛ (បួនម៉ឺន) រៀល ក៏ត្រូវកម្លាំងសមត្ថកិច្ចចុះបង្ក្រាបតែម្ដង និងបានដកហូតថ្នាំញៀនមួយកញ្ចប់ទម្ងន់០,១៤ ក្រាមថ្លឹងទាំងថង់ ។ ក្រោយពេលឃាត់ខ្លួនជនសង្ស័យបានឆ្លើយថា ខ្លួនធ្លាប់រកស៊ីជួញដូរ

ថ្នាំញៀនជាមួយឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ ផន ។ បន្ទាប់ពីសមត្ថកិច្ចបញ្ជូនសំណុំរឿងមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់ តុលាការបានធ្វើការសួរ និងស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] លីម នឹងស្វែងរកអត្តសញ្ញាណតាមនីតិវិធី និងឈានដល់ការឃាត់ខ្លួនជនជាប់ចោទ ០២នាក់ ទី១.ឈ្មោះ [redacted] សុភ័ក្រ ហៅមុីសុភ័ក្រ ភេទប្រុស អាយុ ៣២ឆ្នាំ និងទី២. [redacted] ផន ហៅក្លាមប្រែ ភេទប្រុស អាយុ ៣៥ឆ្នាំ ជាប់ចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

## នាពេលសវនាការ

កិច្ចជំនុំជម្រះបានចាប់ផ្តើម ដោយចៅក្រមជំនុំជម្រះបានប្រកាសបើកសវនាការ និងបានឲ្យក្រឡាបញ្ជីធ្វើការរាយការណ៍អំពីវត្តមានចូលរួមរបស់ភាគី និងសាកសួរយោបល់របស់តំណាងអយ្យការ អំពីដំណើរការរឿងក្តីបន្ត។ ជាយោបល់របស់តំណាងអយ្យការ បានជូនយោបល់ និងស្នើសុំថា ខ្លួនសុំឲ្យមានការជំនុំជម្រះលើរឿងក្តីនេះ ចៅក្រមជំនុំជម្រះក៏បានប្រាប់ជនជាប់ចោទពីបទចោទប្រកាន់ និងបានប្រាប់អំពីសិទ្ធិរបស់ជនជាប់ចោទដើម្បីការពារខ្លួននាពេលជំនុំជម្រះ ៖

-ជនជាប់ចោទឈ្មោះ [redacted] លីម បានឆ្លើយបញ្ជាក់ថា៖ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តំណាងអយ្យការ ។ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៧យប់ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបានដកហូតបានថ្នាំញៀនមួយកញ្ចប់ទម្ងន់០,១៤ ក្រាម ។ ថ្នាំញៀននេះគឺជារបស់ឈ្មោះ [redacted] ផន ដែលបានអោយខ្លួនយកទៅអោយគេ ហើយខ្លួនបានទៅជាមួយឈ្មោះ [redacted] លិ តែមិនទាន់បានអោយគេផង ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន។ ថ្នាំញៀនដែលខ្លួនយកទៅអោយគេ មួយកញ្ចប់ក្នុងតម្លៃ ៥០,០០០ រៀល ។ ខ្លួនមិនស្គាល់ឈ្មោះអ្នកទិញនោះទេ ។ ក្រោយពីយកថ្នាំញៀនអោយគេហើយ ឈ្មោះ ផន បានអោយលុយខ្លួនក្នុងមួយថ្ងៃ ១០,០០០ រៀល ទៅ២០,០០០ រៀល ។ ខ្លួនធ្លាប់បានប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ផន ។ មុនពេលខ្លួនមករកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ ផន ខ្លួនបានរកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ [redacted] សុភ័ក្រ បានប្រហែលជាចំនួន២០ដង មកហើយ ជាប្រភេទម៉ាទឹកកក លក់តម្លៃមួយកញ្ចប់ចាប់ពី៥០,០០០រៀល ទៅ៦០,០០០ រៀល។ ឈ្មោះ [redacted] សុភ័ក្រ ជាមេរបស់ខ្លួន ហើយវាបានអោយលុយខ្លួនក្នុងមួយថ្ងៃ១៥,០០០រៀល ទៅ២០,០០០ រៀល ក្រោយពីខ្លួនបានយកថ្នាំញៀនទៅអោយគេរួចហើយ និងបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នាផងដែរ។ មានពេលខ្លះក្នុងមួយថ្ងៃ ខ្លួនយកថ្នាំញៀនអោយគេពីរ ទៅ បីដង ហើយខ្លួនយកទៅទម្លាក់ចោលនៅក្បែរសេះស។ ក្រោយមកខ្លួនមានជំនាស់ជាមួយឈ្មោះ [redacted] សុភ័ក្រ ខ្លួនក៏បានរកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ [redacted] ផន វិញ។ ខ្លួនស្គាល់ឈ្មោះ [redacted] ផន យូរមកហើយ ពីមុនខ្លួនមិនដឹងថាឈ្មោះ [redacted] ផន ជាអ្នករកស៊ីលក់ថ្នាំញៀននោះទេ ទើបតែថ្មីៗនេះទើបខ្លួនដឹង។ ពេលថ្ងៃ ជួនកាលខ្លួនទៅនៅផ្ទះរបស់ឈ្មោះ [redacted] ផន និងពេលយប់ខ្លួនមករស់នៅផ្ទះរបស់ខ្លួនវិញ។ ក្រោយពីសមត្ថកិច្ចឃាត់ខ្លួន គឺដកហូតបានថ្នាំញៀនមួយកញ្ចប់តម្ងន់០,១៤ ក្រាម និងទូរស័ព្ទដៃម៉ាកណូគៀល ។

-លោកមេធាវី [redacted] បានសួរទៅឈ្មោះ [redacted] លីម បានឆ្លើយបញ្ជាក់ថា៖ នៅពេលខ្លួនយកថ្នាំ-ញៀនទៅអោយគេជាមួយឈ្មោះ [redacted] លិ គឺឈ្មោះ [redacted] ផន ក៏បានដឹងដែរ ព្រោះឈ្មោះ [redacted] ផន មិនទុកចិត្តឈ្មោះ [redacted] លិ ទើបអោយខ្លួនទៅជាមួយឈ្មោះ [redacted] លិ ដើម្បីយកថ្នាំញៀនទៅអោយគេ។

-ជនជាប់ចោទឈ្មោះ [redacted] ផន ហៅក្លាមប្រែ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនទទួលស្គាល់បទចោទប្រកាន់នោះទេ ។ សមត្ថកិច្ចឃាត់ខ្លួន នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ពេលថ្ងៃ នៅបន្ទប់ជួល នៅចំណុចទល់មុខខាវ៉ាអូរខាគូលើ (ហៅកង់ទេះ) សមត្ថកិច្ចបានដកហូតបានទូរស័ព្ទមួយគ្រឿងម៉ាកអូប៉ូពណ៌ខ្មៅ។ ខ្លួន

ស្គាល់ឈ្មោះ [redacted] លីម យូរមកហើយ ព្រោះឈ្មោះ [redacted] លីម ជាអ្នកភូមិជាមួយគ្នា តែឈ្មោះនេះមិនបានមកនៅផ្ទះរបស់ខ្លួននោះទេ ហើយឈ្មោះ [redacted] លីម ក៏ធ្លាប់ចូលមកលេងផ្ទះរបស់ខ្លួនជាធម្មតា។ នៅផ្ទះរបស់ខ្លួន គឺខ្លួនរស់នៅជាមួយប្រពន្ធ និងកូនៗ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក ហើយខ្លួនមិនដែលលក់ថ្នាំញៀននោះទេ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] លីម នៅផ្ទះរបស់គេ (មិនស្គាល់ឈ្មោះ) ទើបបានតែមួយដងនោះទេ។ ថ្នាំញៀនដែលខ្លួនប្រើប្រាស់ជាមួយឈ្មោះ [redacted] លីម គឺបានមកឈ្មោះ [redacted] លិ អាយុប្រហែល ២០ជាង។ ខ្លួនស្គាល់ឈ្មោះ [redacted] សុក្រ តែខ្លួនមិនដឹងថាវារកស៊ីអ្វីនោះទេ។ សមត្ថកិច្ចឃាត់ខ្លួន ដោយសារតែខ្លួនត្រូវបានឈ្មោះ [redacted] លីម ឆ្លើយដាក់ថា ខ្លួនជាអ្នករកស៊ីលក់ថ្នាំញៀន តែខ្លួនមិនបានដឹងរឿងអ្វីនោះទេ។ ឈ្មោះ [redacted] លីម ធ្លាប់ដើរលេងជាមួយឈ្មោះ [redacted] លិ ហើយឈ្មោះ [redacted] លីម ក៏ធ្លាប់មកលេងផ្ទះរបស់ខ្លួនផងដែរ។ ហើយពេលខ្លះវាក៏បានមកដេកលេងពេលថ្ងៃធម្មតា និងមានពេលខ្លះទៀតខ្លួនក៏ហៅវាហូបបាយជាមួយខ្លួនផងដែរ។ ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន និងបានធ្វើតេស្តស្វែងរកសារធាតុញៀនក្នុងខ្លួន ជាលទ្ធផលគឺមិនមានសារធាតុញៀននោះទេ។ កាលក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ មានសមត្ថកិច្ចធ្លាប់អោយខ្លួនធ្វើជាគិញ ដើម្បីចាប់អ្នកលក់ថ្នាំញៀនផងដែរ។ មានពេលខ្លះសមត្ថកិច្ចបានអោយលុយខ្លួនចំនួន ៤០,០០០ រៀល ដើម្បីអោយខ្លួនដើរស៊ើបសួររកអ្នកលក់ថ្នាំញៀន និងអោយខ្លួនរកលេខអ្នកលក់ថ្នាំញៀន ដើម្បីខ្លួនខលទៅធ្វើជាទិញថ្នាំញៀនពីអ្នកលក់ ហើយសមត្ថកិច្ចចាប់ឃាត់ខ្លួនអ្នកលក់ថ្នាំញៀនតែម្តង។ សមត្ថកិច្ចដែលអោយខ្លួនធ្វើជាគិញ គឺលោកវរសេនីយ៍ត្រី [redacted] កែវ បានអោយខ្លួនធ្វើជាគិញរបស់សមត្ថកិច្ច។ ពេលខ្លួនធ្វើជាគិញរបស់សមត្ថកិច្ចមិនបានធ្វើឯកសារបញ្ជាក់អ្វីនោះទេ។ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយឈ្មោះ [redacted] លីម នោះទេ ហើយខ្លួនក៏មិនដឹងថាឈ្មោះ [redacted] លីម ឆ្លើយដាក់ខ្លួន និងមួលបង្កាច់ខ្លួនផងដែរ ព្រោះថាខ្លួនមិនបានដឹងរឿងអ្វីនោះទេ។

-លោកមេធាវី [redacted] បានសួរទៅឈ្មោះ [redacted] ផន ហៅភ្លាមប្រែ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនដឹងថាសមត្ថកិច្ចចាប់ឃាត់ខ្លួនឈ្មោះ [redacted] លីម នោះទេ។ ខ្លួនធ្លាប់ធ្វើជាគិញអោយសមត្ថកិច្ចដើម្បីចាប់អ្នកលក់ថ្នាំញៀនបានចំនួនពីរដងមកហើយ ហើយសមត្ថកិច្ចបានអោយលុយខ្លួនទៅទិញថ្នាំញៀនកាលអំឡុងឆ្នាំ២០២២ ដើម្បីចាប់អ្នកលក់ថ្នាំញៀនទៀតផង ។ ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន គឺមិនបានដកហូតថ្នាំញៀនពីខ្លួននោះទេ ហើយសមត្ថកិច្ចធ្វើតេស្តស្វែងរកសារធាតុញៀនផងដែរ តែជាលទ្ធផលក៏ពុំមានសារធាតុញៀននៅក្នុងខ្លួននោះទេ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ [redacted] លីម នោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ ហៅ [redacted] សុភ័ក្រ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនធ្លាប់ត្រូវគេប្រើអោយទៅទិញថ្នាំញៀន និងយកមកចែកគ្នាជក់។ ខ្លួនមិនធ្លាប់លក់ថ្នាំញៀនអោយគេនោះទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនបានប្រហែល ០៦ខែមកហើយ តាំងពីអំឡុងឆ្នាំ២០២២ ជាប្រភេទម៉ាទឹកកក។ ខ្លួនធ្លាប់ជក់ថ្នាំញៀនជាមួយមនុស្សមិនស្គាល់ឈ្មោះ ដោយមានគ្នា ០២ ទៅ ០៣ នាក់ និងបានចូលលុយគ្នាទិញថ្នាំញៀនយកមកជក់។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] លីម ហើយក៏ធ្លាប់ស្នាក់នៅជាមួយគ្នា។ ខ្លួនធ្លាប់ទិញថ្នាំញៀនយកមកជក់ជាមួយឈ្មោះ [redacted] លីម ផងដែរ។ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចចាប់ឃាត់ខ្លួន តែមិនបានដកហូតបានអ្វីនោះទេ ព្រមទាំងធ្វើតេស្តដើម្បីស្វែងរកសារធាតុញៀនពីក្នុងខ្លួន តែជាលទ្ធផលក៏មិនមានសារធាតុញៀននោះទេ។ ខ្លួនមានទំនាស់គ្នាជាមួយឈ្មោះ [redacted] លីម ក្នុងអំឡុងឆ្នាំ២០២២ ។ ហើយខ្លួនធ្លាប់ជក់ថ្នាំញៀនជាមួយឈ្មោះ [redacted] លីម ដោយជក់ម្តងៗទិញអស់តម្លៃ ២០ដុល្លាអាមេរិក ។ ខ្លួនមិនដឹងថាឈ្មោះ [redacted] លីម ឆ្លើយដាក់ខ្លួននោះទេ។ ខ្លួនមិនបានដឹងរឿងអ្វីនោះទេ។ សមត្ថកិច្ចពេលចាប់ខ្លួន ក៏បានអានដីកាអោយខ្លួនបានដឹងផងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] លីម បានឆ្លើយបញ្ជាក់ថា៖ ខ្លួនសូមឆ្លើយដោយការពិតឈ្មោះ [redacted] សុក័ក្រ បានអោយខ្លួនយកថ្នាំញៀនទៅអោយគេ តាំងពីក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២២ មកម្លេះ ដោយអោយខ្លួនយកទៅទំលាក់ចោលនៅផ្សារសេះស ដោយមួយថ្ងៃពីរ ទៅបីដង។ ហើយឈ្មោះ [redacted] សុក័ក្រ បានអោយលុយខ្លួនក្នុងមួយថ្ងៃចំនួន១០,០០០ រៀល ទៅ ២០,០០០ រៀល។ ក្នុងមួយអាទិត្យខ្លួនយកថ្នាំញៀនទៅទម្លាក់ចោលបីទៅបួនដង ។

-ជនជាប់ចោទឈ្មោះ [redacted] សុក័ក្រ ហៅម៉ី សុក័ក្រ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនធ្លាប់អោយឈ្មោះ [redacted] លីម យកថ្នាំញៀនទៅអោយគេនោះទេ ខ្លួនទទួលស្គាល់ធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] លីម ។ ចំពោះលុយដែរខ្លួនបានទិញថ្នាំញៀនដើម្បីជក់នោះ គឺខ្លួនធ្វើសំណង់បានលុយមក គឺខ្លួនបានយកទៅទិញថ្នាំញៀន។ សមត្ថកិច្ចបានឃាត់ខ្លួន មិនបានដកហូតបានអ្វីពីខ្លួននោះទេ ក្រោយមកសមត្ថកិច្ចក៏បានធ្វើតេស្តដើម្បីស្វែងរកសារជាតុញៀននៅក្នុងខ្លួន ជាលទ្ធផលគឺមិនមានសារជាតុនោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] ផន បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] សុក័ក្រនោះទេ ។

-លោកអនុសេនីយ៍ឯក [redacted] ប្រុស បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនបានចុះបង្ក្រាបដោយផ្ទាល់នោះទេ។ ក្រោយពីខ្លួនទទួលបានព័ត៌មានពីប្រជាពលរដ្ឋថា មានករណីជួញដូរថ្នាំញៀន ដោយមានជនសង្ស័យកំពុងធ្វើសកម្មភាពស្ថិតនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ពេលនោះខ្លួនបានអោយជំនួយការរបស់ខ្លួន ដែលជាមន្ត្រីកងរាជអាវុធហត្ថដឹកនាំកម្លាំងដើម្បីចុះបង្ក្រាបករណីជួញដូរថ្នាំញៀនខាងលើ ។ ក្រោយមកកម្លាំងកងរាជអាវុធហត្ថបានចុះទៅដល់កន្លែងកើតហេតុ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] លីម និងបានដកហូតម្សៅក្រាមពណ៌សថ្លាទម្ងន់ចំនួន០.១៤ ក្រាម និងបានធ្វើតេស្តស្វែងរកសារជាតុញៀនក្នុងខ្លួន ឃើញថា ពិតជាមានសារជាតុញៀនក្នុងខ្លួនឈ្មោះ [redacted] លីម ប្រាកដមែន។ ក្រោយមកសមត្ថកិច្ចក៏បានសួរចម្លើយឈ្មោះ [redacted] លីម ក៏មានលេចចេញឈ្មោះ [redacted] សុក័ក្រ ដែលជាបក្សពួកជាមួយឈ្មោះ [redacted] លីម។ ចំពោះជនជាប់ចោទទាំង ០៣នាក់ខាងលើ ក៏ធ្លាប់មានមន្ត្រីមូលដ្ឋានផ្តល់ព័ត៌មានថាជាមុខសញ្ញា ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀនផងដែរ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បង្ហាញឲ្យឃើញថាៈ បន្ទាប់ពីបានសួរដេញដោល និងបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] លីម, និងស្តាប់ការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងពិនិត្យកស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទ១.ឈ្មោះ [redacted] លីម ទី២.ឈ្មោះ [redacted] សុក័ក្រ និងទី៣.ឈ្មោះ [redacted] ផន ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ ប្រាកដមែន ។ ទោះជានៅក្នុងពេលសវនាការនេះ ជនជាប់ចោទឈ្មោះ [redacted] សុក័ក្រ និងឈ្មោះ [redacted] ផន បានឆ្លើយបដិសេធប្រហាក់ប្រហែលគ្នាថា ពួកគេធ្លាប់ស្គាល់ឈ្មោះ [redacted] លីម និងធ្លាប់ប្រើប្រាស់ថ្នាំញៀន តែមិនបានអោយឈ្មោះ [redacted] លីម យកថ្នាំញៀនទៅអោយគេនោះទេ ។ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ [redacted] ផន បានឆ្លើយបញ្ជាក់ថា ខ្លួនធ្លាប់ជាគិញរបស់សមត្ថកិច្ចនោះ គឺពុំមានឯកសារបញ្ជាក់នោះទេ ព្រោះអ្នកដែលធ្វើជាគិញអោយសមត្ថកិច្ចបានលុះត្រាតែមានការយល់ព្រម ឬទទួលស្គាល់ពីតំណាងអយ្យការផងដែរ តែជននេះពុំបានបង្ហាញឯកសារបញ្ជាក់នោះទេ។ ចម្លើយរបស់ឈ្មោះ [redacted] ផន និងឈ្មោះ [redacted] សុក័ក្រ គ្រាន់តែជាការឆ្លើយ



Scanned with CamScanner

ដោះសារគេចវេសពីការទទួលខុសត្រូវនូវទង្វើរបស់ខ្លួនតែប៉ុណ្ណោះ។ ហេតុដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ២១ អ.យ.គ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ទុកដដែល និងស្នើសុំតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទាំងបីនាក់ខាងទៅតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ស៊ីន ផន

ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បន្ទាប់ពីបានស្ដាប់ចម្លើយជនជាប់ចោទរួចមកៈ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផន ស្នើសុំដាក់បញ្ចូលសេចក្ដីសន្និដ្ឋានការពារកូនក្ដីរបស់ខ្លួន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ មកសាលាដំបូងខេត្តកែប និងស្នើសុំធ្វើសេចក្ដីសន្និដ្ឋានត្រួសៗបន្ថែមថាៈ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចបានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅចំណុចចាងណាង (ផ្លូវលំចូលសីករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដោយឃាត់ខ្លួនឈ្មោះ [redacted] លីម ក្រោយមកឈ្មោះ [redacted] លីម បានឆ្លើយដាក់បន្ទុក និងមួលបង្កាច់មកលើកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ផន ដែលកូនក្ដីរបស់ខ្លួនមិនបានព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ [redacted] លីម នោះទេ ហើយនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចឃាត់ខ្លួនកូនក្ដីរបស់ខ្លួននៅក្នុងបន្ទប់ តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ និងបានធ្វើការឆែកឆេរបន្ទប់មិនមានថ្នាំញៀន ព្រមទាំងបានធ្វើតេស្តស្វែងរកសារធាតុញៀន ជាលទ្ធផល កូនក្ដីរបស់ខ្លួនមិនមានសារធាតុញៀនក្នុងខ្លួនផងដែរ។ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ផន ពីមុនក៏ធ្លាប់ធ្វើជាគិញអោយសមត្ថកិច្ចក្នុងការតាមចាប់អ្នកដល់ថ្នាំញៀនផងដែរ។ ហេតុដូច្នេះ បើយោងតាម៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា វិមតិសង្ស័យត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច មិនតែប៉ុណ្ណោះមាត្រា៣៥០ នៃក្រមនីតិវិធីបានចែងថា "ប្រសិនបើតុលាការយល់ឃើញ ថាអំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ" ដូចនេះគ្មានពិរុទ្ធភាពលើកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ផន នោះទេ ក្នុងនាមជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ផន ស្នើសុំប្រធានជំនុំជម្រះសម្រេចអោយកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ផន រួចផុតពីបទចោទប្រកាន់ព្រោះថា កូនក្ដីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

## សម្ដីចុងក្រោយការពារខ្លួន និងសំណូមពររបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] លីម បានស្នើសុំតុលាការបន្ធូរបន្ថយទោស ព្រោះខ្លួនបានដឹងពីកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ ហៅ [redacted] សុភ័ក្រ ខ្លួនស្នើសុំតុលាការរួចផុតការចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] ផន ហៅ ក្ដាមប្រែ ខ្លួនស្នើសុំតុលាការសម្រេចអោយខ្លួនរួចផុតពីបទចោទប្រកាន់។

## សាលាដំបូង

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយការពារខ្លួន និងសំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្ដុតាងពាក់ព័ន្ធនានា ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ

-ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ និងពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ

# សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ ដើម្បីស្វែងរកការពិតនៃសំណុំរឿងក្តីព្រហ្មទណ្ឌនេះ តាមរយៈការស្តាប់ចម្លើយរបស់ភាគីទាំងឡាយដែលពាក់ព័ន្ធ និងការពិនិត្យភស្តុតាងដែលបានស្វែងរកដោយមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ តុលាការយល់ឃើញថា៖

**១.បណ្តឹងចោទប្រកាន់**

តំណាងអយ្យការ និងចៅក្រមស៊ើបសួរ បានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើជនជាប់ចោទ៖

១.ឈ្មោះ [redacted]លីម ភេទប្រុស អាយុ ៣៣ឆ្នាំ (កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៨៩) ជនជាតិខ្មែរ ។

ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted]សុភ័ក្រ ហៅ[redacted]សុភ័ក្រ ភេទប្រុស អាយុ ៣២ឆ្នាំ (កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨៩) ជនជាតិខ្មែរ ។

៣.ឈ្មោះ[redacted] ផន ហៅក្តាមប្រែ ភេទប្រុស អាយុ ៣៥ឆ្នាំ (កើតឆ្នាំ១៩៨៨) ជនជាតិខ្មែរ ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្ម-ទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.ការវិនិច្ឆ័យចំពោះបទចោទប្រកាន់**

**ក.បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**

-តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា ៖

ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសនូវសារធាតុញៀន។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុ ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

[...]

-យោងទៅតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]លីម បានឆ្លើយថាៈ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តំណាងអយ្យការ ។ កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង០៧យប់ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបានដកហូតបានថ្នាំញៀនមួយកញ្ចប់ទម្ងន់០,១៤ក្រាម។ ថ្នាំញៀននេះគឺជារបស់ឈ្មោះ [redacted] ផន ដែលបានអោយខ្លួនយកទៅអោយគេ ហើយខ្លួនបានទៅជាមួយឈ្មោះ[redacted]លិ តែមិនទាន់បានអោយគេផង ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន ។ ថ្នាំញៀនដែលខ្លួនយកទៅអោយគេ មួយកញ្ចប់ក្នុងតម្លៃ ៥០,០០០ រៀល ។ ក្រោយពីយកថ្នាំញៀនអោយគេហើយ ឈ្មោះ ផន បានអោយលុយខ្លួនក្នុងមួយថ្ងៃ ១០,០០០ រៀល ទៅ ២០,០០០ រៀល និងបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នា ។ មុនពេលខ្លួនមករកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ ផន



Scanned with CamScanner

ខ្លួនបានរកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ [redacted] សុភ័ក្រ បានប្រហែលជាចំនួន ២០ដង មកហើយ ជាប្រភេទម៉ាទឹកកក លក់តម្លៃមួយកញ្ចប់ចាប់ពី៥០,០០០ រៀល ទៅ៦០,០០០ រៀល ។ ឈ្មោះ[redacted] សុភ័ក្រ ជាមេរបស់ខ្លួន ហើយវាបានអោយលុយខ្លួនក្នុងមួយថ្ងៃ១៥,០០០ រៀល ទៅ២០,០០០ រៀល និងបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នាផងដែរ ក្រោយពីខ្លួនបានយកថ្នាំញៀនទៅអោយគេរួចហើយ។ ក្រោយមកខ្លួនមានជំនាស់ជាមួយឈ្មោះ [redacted] សុភ័ក្រ ខ្លួនក៏បានរកស៊ីលក់ថ្នាំញៀនជាមួយឈ្មោះ[redacted]ផន វិញ។

-យោងទៅតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផន ហៅក្តាមប្រៃ បានឆ្លើយថា: សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ពេលថ្ងៃ នៅបន្ទប់ជួល នៅចំណុចទល់មុខខារ៉ាអូរខាគូរលី (ហៅកង់រទេះ) តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ ។ ខ្លួនស្គាល់ឈ្មោះ[redacted]លីម យូរមកហើយ ព្រោះឈ្មោះ[redacted] លីម ជាអ្នកភូមិជាមួយគ្នា តែឈ្មោះនេះមិនបានមកនៅផ្ទះរបស់ខ្លួននោះទេ ហើយឈ្មោះ[redacted]លីម ក៏ធ្លាប់ចូលមកលេងផ្ទះរបស់ខ្លួនជាធម្មតា។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក ហើយខ្លួនមិនដែលលក់ថ្នាំញៀននោះទេ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] លីម នៅផ្ទះរបស់គេ (មិនស្គាល់ឈ្មោះ) ទើបបានតែមួយដងនោះទេ។ ថ្នាំញៀនដែលខ្លួនប្រើប្រាស់ជាមួយឈ្មោះ[redacted] លីម គឺបានមកឈ្មោះ[redacted]លិ អាយុប្រហែល ២០ជាង។ ខ្លួនស្គាល់ឈ្មោះ [redacted] សុភ័ក្រ តែខ្លួនមិនដឹងថាវារកស៊ីអ្វីនោះទេ។ ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន និងបានធ្វើតេស្តស្វែងរកសារជាតុញៀនក្នុងខ្លួន ជាលទ្ធផលគឺមិនមានសារជាតុញៀននោះទេ។ កាលក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ មានសមត្ថកិច្ចធ្លាប់អោយខ្លួនធ្វើជាគិញ ដើម្បីចាប់អ្នកលក់ថ្នាំញៀនផងដែរ។ ពេលខ្លួនធ្វើជាគិញរបស់សមត្ថកិច្ចមិនបានធ្វើឯកសារបញ្ជាក់អ្វីនោះទេ។

-យោងទៅតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ ហៅ[redacted] សុភ័ក្រ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនធ្លាប់ត្រូវគេប្រើអោយទៅទិញថ្នាំញៀន និងយកមកចែកគ្នាជក់។ ខ្លួនមិនធ្លាប់លក់ថ្នាំញៀនអោយគេនោះទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនបានប្រហែល០៦ ខែមកហើយ តាំងពីអំឡុងឆ្នាំ២០២២ ជាប្រភេទម៉ាទឹកកក។ ខ្លួនធ្លាប់ជក់ថ្នាំញៀនជាមួយមនុស្សមិនស្គាល់ឈ្មោះ ដោយមានគ្នា០២ ទៅ ០៣នាក់ និងបានចូលលុយគ្នាទិញថ្នាំញៀនយកមកជក់។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] លីម ហើយក៏ធ្លាប់ស្នាក់នៅជាមួយគ្នា ។ ខ្លួនធ្លាប់ទិញថ្នាំញៀនយកមកជក់ជាមួយឈ្មោះ [redacted]លីម ផងដែរ។ ខ្លួនមានទំនាស់គ្នាជាមួយឈ្មោះ [redacted]លីម ក្នុងអំឡុងឆ្នាំ២០២២ ហើយខ្លួនធ្លាប់ជក់ថ្នាំញៀនជា មួយឈ្មោះ កៅ លីម ដោយជក់ម្តងៗទិញអស់តម្លៃ ២០ដុល្លាអាមេរិក ។

-យោងទៅតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]លីម គឺមានភាពស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ ហៅ[redacted] សុភ័ក្រ ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted]ផន ហៅក្តាមប្រៃ ភេទប្រុស អាយុ ៣៥ឆ្នាំ ព្រមទាំងស្របគ្នាទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានចុះបង្ក្រាបបទល្មើសគ្រឿងញៀន ក៏ដូចកស្តុតាងដាក់បន្ទុកទាំងឡាយខាងលើ ។

-នៅពេលសមត្ថកិច្ចអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទ ចេញដោយចៅក្រមស៊ើបសួរ សមត្ថកិច្ចក៏បានស្រាវជ្រាវស្វែងរកចាប់ខ្លួនឈ្មោះ [redacted] សុភ័ក្រ ហៅម៉ី សុភ័ក្រ និងជនត្រូវចោទឈ្មោះ [redacted] ផន ហៅក្តាមប្រៃ មកចំពោះមុខចៅក្រមស៊ើបសួរ ប៉ុន្តែនៅពេលនាំខ្លួននោះ សមត្ថកិច្ចពុំបានរកឃើញ ឬដកហូតវត្ថុចាប់យកជាថ្នាំញៀនពីជននេះឡើយ។ ដូច្នេះការវិនិច្ឆ័យបទជួញដូរដោយខុសច្បាប់នូវសារជាតុញៀនពុំពឹងផ្អែកទៅលើបរិមាណជាតុសុទ្ធនៃសារជាតុញៀននោះឡើយ ពោល គឺសម្រេចលើមូលដ្ឋានផ្តន្ទាទោសទូទៅតាមមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-យោងទៅតាមចម្លើយជនជាប់ចោទ និងភស្តុតាងនានាដែលកសាងដោយមន្ត្រីនគរបាលយុត្តិធម៌ និងកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ឃើញថា៖ អង្គហេតុដែលជនជាប់ចោទឈ្មោះ[redacted]លីម បានសារភាពដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted]ផន និងឈ្មោះ [redacted]សុភ័ក្ត្រ មានភាពស៊ីសង្វាក់គ្នា និងសមហេតុសមផល ដែលអាចអោយតុលាការជឿបានថា៖ ជនជាប់ចោទទាំងបីនាក់ ពិតជាបានប្រព្រឹត្តបទល្មើសនៃការជួញដូរគ្រឿងញៀន ដូចការចោទប្រកាន់របស់តំណាងអយ្យការ ប្រាកដមែន ។ ម៉្យាងទៀត ពុំមានភស្តុតាងណាដែលបញ្ជាក់ថាជនជាប់ចោទឈ្មោះ[redacted]លីម ធ្លាប់មានទំនាស់ណាមួយ ឬការគុំគួនណាមួយ ដែលឆ្លើយទម្លាក់កំហុសអោយគ្នាទៅវិញទៅមកនោះទេ ។ លើសពីនេះទៀត អង្គហេតុនៃការមានទំនាក់ទំនងរវាងជនជាប់ចោទឈ្មោះ[redacted]លីម និងឈ្មោះ [redacted]ផន និងឈ្មោះ [redacted] សុភ័ក្ត្រ គឺមានភាពច្បាស់លាស់ ជាពិសេសគឺទំនាក់ទំនងនៃការជួញដូរគ្រឿងញៀន ដើម្បីបានកម្រៃ ក៏ដូចការប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ផងដែរ ។

-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ[redacted] លីម ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ[redacted]សុភ័ក្រ ហៅ[redacted]សុភ័ក្រ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរនិងឈ្មោះ[redacted]ផន ហៅក្តាមប្រៃ ភេទប្រុស អាយុ ៣៥ឆ្នាំ ។

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

**ខ.បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

-តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា ៖

ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាទី ១ និងតារាងទី ២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០. ០០០ (មួយលាន) រៀល ។

[...]

-យោងទៅតាម៖ កំណត់ហេតុធ្វើតេស្តទឹកនោម និងវេចខ្ចប់វត្ថុតាងរបស់ជនសង្ស័យឈ្មោះ[redacted] លីម ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។

-យោងទៅតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted]លីម គឺមានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានចុះបង្ក្រាបបទល្មើសគ្រឿងញៀន ក៏ដូចជាភស្តុតាងជាការធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀននៅក្នុងខ្លួន ដែលបង្ហាញថា: "វិជ្ជមានសារធាតុញៀន" ។

-យោងទៅតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា៖ ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ។ យ៉ាងណាមិញ ការស្វែងរកភស្តុតាងនៅគ្រប់ដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ គឺពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted]លីម ភេទប្រុស អាយុ ៣៣ឆ្នាំ (កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៨៩) ជនជាតិខ្មែរ ធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរនោះទេ។ ម៉្យាងទៀត ជនប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ក៏ជាជនរងគ្រោះម្នាក់ បណ្តាលមកពីសារធាតុញៀនផងដែរ ។

-គ្មានកស្តុតាងដាក់បន្ទុក និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted]លីម ភេទប្រុស អាយុ ៣៣ឆ្នាំ (កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៨៩) ជនជាតិខ្មែរ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារៈធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសីករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៤៥ នៃច្បាប់ស្តីពីកាត្រួតពិនិត្យគ្រឿងញៀន។។

**៣.ការវិនិច្ឆ័យចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំ**

-តំណាងអយ្យការប្តឹងសុំចៅក្រមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផន ស្នើសុំតុលាការសម្រេចលើកលែងការចោទប្រកាន់លើកូនក្តីរបស់ខ្លួន ព្រោះកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងមិនបានដឹងរឿងអ្វីនោះទេ គឺឈ្មោះ កៅ លីម ឆ្លើយដាក់ និងមួលបង្កាច់កូនក្តីរបស់ខ្លួនតែប៉ុណ្ណោះ ។

-ជនជាប់ចោទបានធ្វើកំណត់សម្គាល់ខ្លីៗថាៈ សំណូមពរឲ្យតុលាការសម្រេចរួចផុតពីបទចោទប្រកាន់ ។

-តាមបញ្ញត្តិមាត្រា ៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាៈ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានមូលដ្ឋានត្រឹមត្រូវសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ គប្បីតុលាការពិចារណាតាមច្បាប់ ។

-ការស្នើសុំលើកលែងការចោទប្រកាន់របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] ផន និងកំណត់សម្គាល់របស់ជនជាប់ចោទខាងលើ គប្បីចៅក្រមជំនុំជម្រះ ទទួលយកមកពិចារណា តាមនីតិវិធីច្បាប់ជាធរមាន។

**៤.ការវិនិច្ឆ័យចំពោះសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ**

ជនជាប់ចោទទាំងបីនាក់ខាងលើ គឺជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺពុំមានកស្តុតាងណាមួយបញ្ជាក់ថាជននេះមានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទទាំងបីនាក់ខាងលើពិតជាមានស្មារតីយល់ដឹងអំពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា៣៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

**៥.ការវិនិច្ឆ័យចំពោះទោស និងរបបប្រកាសទោស**

**ក.ចំពោះទោស**

-ចំពោះជនជាប់ចោទឈ្មោះ [redacted]លីម តុលាការពិចារណាលើកយកការសម្រេចទោសដាក់ពន្ធនាគារដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ មុន អំឡុងពេល និងក្រោយពេលប្រព្រឹត្តអំពើល្មើស ដោយហេតុថាជនជាប់ចោទពិតជាមានចេតនាក្នុងការជួញដូរនូវសារធាតុញៀនប្រាកដមែន ប៉ុន្តែជននេះបានសារភាពពល់អំពើដែលខ្លួនបានប្រព្រឹត្ត និងសន្យាថានឹងឈប់ប្រព្រឹត្តអំពើខុសច្បាប់ទៀតហើយ។ ម៉្យាងទៀត ជននេះបានសារភាព និងបង្កភាពងាយស្រួលក្នុងការផ្តល់ចម្លើយ ក៏ដូចជាបង្ហាញអង្គហេតុពាក់ព័ន្ធទៅនឹងជនជាប់ចោទផ្សេងទៀត ។ ដូច្នេះ តុលាការពិចារណាផ្តន្ទាទោសទៅលើជននេះ ក្នុងកម្រិតព្រំដែននៃទោសដែលបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន បានចែងឲ្យផ្តន្ទាទោស ។

-ចំពោះជនជាប់ចោទឈ្មោះ [redacted] ផន ហៅក្តាម ប្រៃ និងឈ្មោះ [redacted] សុភ័ក្រ ហៅ[redacted]សុភ័ក្រ តុលាការពិចារណាលើកយកការសម្រេចទោសដាក់ពន្ធនាគារ ដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ មុន អំឡុងពេល និងក្រោយពេលប្រព្រឹត្តអំពើល្មើស ដោយហេតុថាជនជាប់ចោទទាំងពីរនាក់នេះពិតជាមានចេតនា

ក្នុងការជួញដូរនូវសារធាតុញៀនប្រាកដមែន និងទទួលស្គាល់កំហុស ។ ម្យ៉ាងទៀត ជននេះសុទ្ធតែមានកម្រិតវប្បធម៌តិចតួច និងពុំមានមុខរបរដើម្បីបម្រើឲ្យជីវភាពប្រចាំថ្ងៃនោះទេ ។ លើសពីនេះទៅទៀត ពុំមានភស្តុតាងណាបញ្ជាក់ថាជននេះធ្លាប់ជាប់ពន្ធនាគារពីមុនមកនោះទេ ដែលជននេះអះអាងថាទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។ ដូច្នេះ តុលាការពិចារណាផ្ដន្ទាទោសទៅលើជននេះ ក្នុងកម្រិតព្រំដែននៃទោសដែលបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីការត្រួតពិនិត្យគ្រឿងញៀន បានចែងឲ្យផ្ដន្ទាទោស ។

**ខ.ចំពោះរបបប្រកាសទោស**

តាមបញ្ញត្តិមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តុលាការសម្រេចយកការប្រកាសមូលទោស ដោយការផ្ដន្ទាទោសដាក់ពន្ធនាគារទៅលើជនជាប់ចោទទាំងបីនាក់ខាងលើ តែមួយមុខប៉ុណ្ណោះ ។

**៦.ការវិនិច្ឆ័យចំពោះវត្ថុចាប់យក**

-វត្ថុចាប់យក ដែលត្រូវបានដកហូតដោយមន្ត្រីនគរបាលយុត្តិធម៌ រួមមានៈ

១.ម្សៅក្រាមពណ៌សថ្លា ចំនួន០១កញ្ចប់ ទម្ងន់ ០,១៤ ក្រាម (ថ្លឹងទាំងថង់)។

២.ទូរស័ព្ទចំនួន ០១គ្រឿង ម៉ាកអ៊ិនចុចពិល ។

ដូចមានក្នុងកំណត់ហេតុទទួលយកវត្ថុតាង ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ ។

៣.ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅ ចំនួន ០១គ្រឿង (ខូច)។

ដូចមានក្នុងកំណត់ហេតុទទួលយកវត្ថុតាង ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ។

-តុលាការយល់ឃើញថាៈ វត្ថុចាប់យកទី១ គឺជាសារធាតុញៀន ដែលធ្វើឲ្យប៉ះពាល់សុខភាពសាធារណៈ និងជាវត្ថុចាប់យកបម្រើឲ្យបទល្មើសជួញដូរគ្រឿងញៀន ដែលមិនបម្រើឲ្យផលប្រយោជន៍នៃទ្រព្យសម្បត្តិរដ្ឋឡើយ។ ដូច្នេះ គប្បីរឹបអូសវត្ថុចាប់យកទី១ ខាងលើ ដើម្បីយកទៅបំផ្លាញចោល ។

-តុលាការយល់ឃើញថាៈ វត្ថុចាប់យកទី២ និងទី៣ ខាងលើ គឺជាសម្ភារៈដើម្បីប្រព្រឹត្តបទល្មើស និងជាផលដែលបានមកពីបទល្មើស ដូច្នេះ គប្បីរឹបអូសទុកជាសម្បត្តិរដ្ឋ ។

**<u>វិនិច្ឆ័យសេចក្ដី</u>**

**<u>ហេតុដូច្នេះសម្រេច</u>**

I. ផ្ដន្ទាទោសលើជនជាប់ចោទៈ

១.ឈ្មោះ [redacted]លីម ភេទប្រុស កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្ដោះអាសន្ន ។

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីកាត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted]សុភ័ក្រ ហៅ[redacted]សុភ័ក្រ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្ដោះអាសន្ន ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករង ក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ឈ្មោះ [redacted] ផន ហៅ ក្លាមប្រៃ ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករង ក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

II.ឲ្យជនជាប់ចោទៈ

១.ឈ្មោះ [redacted]លីម ភេទប្រុស កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៨៩ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

រួចផុតពីបទចោទប្រកាន់ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចាងណាង (ផ្លូវលំចូលសឹករងក្រុងកែប) ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

III.រឹបអូសវត្ថុចាប់យករួមមានៈ

១.ម្សៅក្រាមពណ៌សថ្លា ចំនួន០១កញ្ចប់ ទម្ងន់ ០,១៤ ក្រាម (ថ្លឹងទាំងថង់)។

ដើម្បីយកទៅបំផ្លាញចោល ។

២.ទូរស័ព្ទចំនួន ០១គ្រឿង ម៉ាកអ៊ិនចុចពិល ។

៣.ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅ ចំនួន ០១គ្រឿង (ខូច)។

ដើម្បីទុកជាសម្បត្តិរដ្ឋ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃ០២ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]លីម, ឈ្មោះ [redacted]សុភ័ក្រ ហៅ[redacted]សុភ័ក្រ និងឈ្មោះ [redacted]ផន ហៅ ក្លាម ប្រៃ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខានិងត្រា-[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខានិងត្រា-[redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ខេត្តកែប ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣
**ក្រឡាបញ្ជីសវនាការ**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]